ការិយាល័យកណ្ដាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

# ការកែសម្រួលតួលេខ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និង សាធារណជនទាំងអស់ មេត្តាជ្រាបថា ដោយសារបញ្ហាបច្ចេកទេសក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស របស់ធនាគារ អេស៊ីលីដា ដែលបានធ្វើការផ្សព្វផ្សាយលើគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ធនាគារ អេស៊ីលីដា សូមធ្វើការកែសម្រួលតួលេខ ក្នុងកំណត់សម្គាល់លេខ៩ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ជាភាសាខ្មែរ នៅទំព័រ៨៧ បន្ទាត់ “មូលប័ត្របំណុល” កូឡោន “នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក” ដែលបានបង្ហាញសមតុល្យ “២.៤៣៣.៨៣៤.១០៣” និងជាភាសាអង់គ្លេស នៅទំព័រ៦៨ បន្ទាត់ “Debt securities” កូឡោន “31 December 2021 US$” ដែលបានបង្ហាញសមតុល្យ “2,433,834,103” ត្រូវបានលុបចោល ហើយធ្វើការកែសម្រួលទៅជា “សូន្យ” វិញ។ ការកែសម្រួលនេះ គឺមិនធ្វើឱ្យប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ទាំងមូលនោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP